ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
# ស្តីពី
# ករណីជាសះស្បើយចំនួន ០៥នាក់ និងមិនមានករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មី
# នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២០

ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបពីស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា មានដូចខាងក្រោមនេះ ៖

**១. ស្ថានភាពជំងឺកូវីដ-១៩ នៅទូទាំងប្រទេស ៖** គិតត្រឹមម៉ោង ០៧:០០នាទីព្រឹក នៃថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០ មានដូចតារាងខាងក្រោមនេះ ៖

| ល.រ. | បរិយាយ | សរុប (នាក់) | ស្រី (នាក់) | ប្រុស (នាក់) | ផ្សេងៗ |
|---|---|---|---|---|---|
| ១. | **អ្នកមានវីរុសកូវីដ-១៩ ៖** | | | | |
| | ១.១. ព្រឹត្តិការណ៍សហគមន៍ ២៨វិច្ឆិកា | ៤១ | ១៩ | ២២ | អ្នកឆ្លងថ្មី៖ ០នាក់ |
| | ១.២. អ្នកដំណើរចូលមកកម្ពុជា និងអ្នកឆ្លងបន្តនៅក្នុងប្រទេស | ៣២១ | ៦៧ | ២៥៤ | អ្នកឆ្លងថ្មី៖ ០នាក់ |
| | **សរុបអ្នកមានវីរុសកូវីដ-១៩** | **៣៦២** | **៨៦** | **២៧៦** | អ្នកឆ្លងថ្មី៖ ០នាក់ |
| ២. | **អ្នកព្យាបាលជាសះស្បើយ ៖** | | | | |
| | ២.១. ព្រឹត្តិការណ៍សហគមន៍ ២៨វិច្ឆិកា | ១៣ | ០៤ | ០៩ | អ្នកជាសះស្បើយថ្មី៖**០៥នាក់** |
| | ២.២. អ្នកដំណើរចូលមកកម្ពុជា និងអ្នកឆ្លងបន្តនៅក្នុងប្រទេស | ៣១១ | ៦៥ | ២៤៦ | អ្នកជាសះស្បើយថ្មី៖០នាក់ |
| | **សរុបអ្នកព្យាបាលជាសះស្បើយ** | **៣២៤** | **៦៩** | **២៥៥** | អ្នកជាសះស្បើយថ្មី៖**០៥នាក់** |
| ៣. | **អ្នកកំពុងសម្រាកព្យាបាល ៖** | | | | |
| | ៣.១. មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត | ២២ | ០៩ | ១៣ | |
| | ៣.២. មណ្ឌលសុខភាពចាក់អង្រែ | ១០ | ០៥ | ០៥ | |
| | ៣.៣. មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺរបេង និងហង់សិន | ០៦ | ០៣ | ០៣ | |
| | **សរុបអ្នកកំពុងសម្រាកព្យាបាល** | **៣៨** | **១៧** | **២១** | |



ទីស្តីការក្រសួងសុខាភិបាល ផ្លូវលេខ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០/៨៨៤ ៩០៩

## ២. ព័ត៌មានប្រចាំថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២០

**ក. មានករណីជាសះស្បើយ ៖ ចំនួន ០៥នាក់ ដែលជាអ្នកពាក់ព័ន្ធទៅនឹង ព្រឹត្តិការណ៍សហគមន៍ ២៨វិច្ឆិកា**

-ស្ត្រីជនជាតិខ្មែរ អាយុ ៦៨ឆ្នាំ មានអាសយដ្ឋាននៅសង្កាត់ទួលទំពូង១ ខណ្ឌចំការមន រាជធានីភ្នំពេញ ត្រូវជាម្តាយស្ត្រី អាយុ ៣៦ឆ្នាំ ដែលមានស្វាមីជាអនុប្រធាននាយកដ្ឋានពន្ធនាគារនៃក្រសួងមហាផ្ទៃ។

-ស្ត្រីជនជាតិខ្មែរ អាយុ ២៥ឆ្នាំ និងទារកប្រុស (ជនជាតិខ្មែរ) អាយុ ០៧ខែ មានអាសយដ្ឋាននៅសង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ជាប្អូនស្រីរបស់អ្នកបើកបរឲ្យឯកឧត្តម អគ្គនាយកពន្ធនាគារ។

- បុរសជនជាតិខ្មែរ អាយុ ២៣ឆ្នាំ មានអាសយដ្ឋានស្នាក់នៅសង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ជាបុគ្គលិកធនាគារចិន (ផ្លូវព្រះមុន្នីវង្ស) រាជធានីភ្នំពេញ។

សូមកត់សម្គាល់ថា៖ បុគ្គលទាំងបួននាក់ខាងលើ ត្រូវបានព្យាបាលជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្តអវិជ្ជមានវីរុសកូវីដ-១៩ ចំនួន ០២ដង និងត្រូវបានអនុញ្ញាតឲ្យចេញពីមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត រាជធានីភ្នំពេញ។

- បុរសជនជាតិខ្មែរ អាយុ ២៣ឆ្នាំ មានអាសយដ្ឋានស្នាក់នៅម៉ុស្តុប NOKIA ខណ្ឌសែនសុខ រាជធានីភ្នំពេញ ជាបុគ្គលិកហាង Pedro ផ្លូវព្រះសីហនុ ត្រូវបានព្យាបាលជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្តអវិជ្ជមានវីរុសកូវីដ-១៩ ចំនួន ០២ដង និងត្រូវបានអនុញ្ញាតឲ្យចេញពីមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺរបេង និងហង់សិន រាជធានីភ្នំពេញ។

**ខ. មិនមានករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មី ៖** នៅថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ២០២០

**គ. លទ្ធផលធ្វើតេស្តអ្នកប៉ះពាល់ក្នុង "ព្រឹត្តិការណ៍សហគមន៍ ២៨វិច្ឆិកា"**

វត្ថុសំណាកនៅសល់ពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២០ ចំនួន ២២៤សំណាក និងវត្ថុសំណាកនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២០ ចំនួន ៦៧៣សំណាក សរុបមានចំនួនទាំងអស់ ៨៩៧សំណាក ដែលនៅក្នុងចំនួននេះ មានចំនួន ៤២៦សំណាក ត្រូវបានធ្វើវិភាគដោយវិទ្យាស្ថានប៉ាស្ទ័រកម្ពុជានៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២០ គឺមានលទ្ធផលអវិជ្ជមានវីរុសកូវីដ-១៩ ទាំងអស់ ។ ដោយឡែក មាននៅសល់វត្ថុសំណាកចំនួន ២៤៧សំណាកទៀត ដែលត្រូវធ្វើវិភាគបន្តនៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០ (ដោយសារវត្ថុសំណាកទាំងនេះ ទទួលបានក្រោយម៉ោង ១៧:០០នាទីល្ងាចនៃថ្ងៃដដែល)។

សរុបអ្នកជំងឺកូវីដ-១៩ ដែលបានរកឃើញពាក់ព័ន្ធ "ព្រឹត្តិការណ៍សហគមន៍ ២៨វិច្ឆិកា" ពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២០ ដល់ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២០ មានចំនួន ៤១នាក់ (ស្រី ១៩នាក់ និងប្រុស ២២នាក់) ដែលនៅក្នុងចំនួននេះ មានអ្នកជាសះស្បើយ សរុបចំនួន ១៣នាក់ (ស្រី ០៤នាក់ និងប្រុស ០៩នាក់)។

## ៣. ការអំពាវនាវសម្រាប់អ្នកដែលពាក់ព័ន្ធទៅនឹង "ព្រឹត្តិការណ៍សហគមន៍ ២៨វិច្ឆិកា"

ក្រសួងសុខាភិបាល សូមធ្វើការក្រើនរំលឹកសារជាថ្មីជូនដល់បងប្អូនប្រជាពលរដ្ឋថា ដោយសារមានបុរសជាអ្នកជំងឺកូវីដ-១៩ម្នាក់ (មុនពេលរកឃើញថាមានវីរុសកូវីដ-១៩) ធ្លាប់បានទៅអង្គុយពិសារកាហ្វេនៅហាងឈ្មោះ Hidden Coffee ដែលមានទីតាំងនៅហាងលេខ ១២៥ ផ្លូវ ២០០២ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ វេលាម៉ោង ១៥:៣០នាទី នាថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០២០ ក្រសួង សុខាភិបាល សូមអំពាវនាវដល់បងប្អូនប្រជាពលរដ្ឋដែលធ្លាប់បានចូលទៅហាងកាហ្វេនេះ នៅថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង ១៥:៣០នាទី ដល់ម៉ោង ១៦:០០នាទីរសៀល សូមអញ្ជើញទៅធ្វើតេស្តនៅវិទ្យាស្ថានជាតិសុខ

ភាពសាធារណៈ វៀងរាល់ម៉ោងធ្វើការ និងសូមលោកអ្នកធ្វើចត្តាឡីស័កនៅតាមផ្ទះរបស់ខ្លួនឲ្យបានគ្រប់ចំនួន ១៤ថ្ងៃ តាមការណែនាំរបស់ក្រសួងសុខាភិបាល ហើយត្រូវតាមដានសុខភាពផ្ទាល់ខ្លួនឲ្យបានហ្មត់ចត់ជាទីបំផុត។ ប្រសិនបើមានបញ្ហាសុខភាព សូមទាក់ទងទៅលេខទូរស័ព្ទដែលមានជូននៅខាងក្រោមនេះស្រាប់។

ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្រុមគ្រូពេទ្យស្ម័គ្រចិត្ត**សម្តេចតេជោ ទីនា** អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលគ្រប់គ្រង និងបង្ការជំងឺឆ្លងសហរដ្ឋអាមេរិក វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា វិទ្យាស្ថានជាតិសុខភាពសាធារណៈ និងមន្ទីរពិសោធន៍នៃមន្ទីរពេទ្យខេត្តសៀមរាប ដែលបានខិតខំបំពេញភារកិច្ចបានល្អប្រសើរបំផុត ក្នុងការជួយពិនិត្យសុខភាព និងស្រាវជ្រាវរកករណីកូវីដ-១៩ ព្រមទាំងអ្នកប៉ះពាល់ទាំងអស់កន្លងមក រួមទាំងការដាក់វិធានការនានា ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជា។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវត្តន៍នៃបញ្ហាសុខភាព តាមទំព័រហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៤៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃព្រហស្បតិ៍ ៣កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០